St Leonard's College

An education for life.

# ដំនើរការដាក់ពាក្យសិស្សអន្តរជាតិ និង គោលការណ៍



# ដំណើរការដាក់ពាក្យសិស្សអន្តរជាតិ និង គោលការណ៍

## ដំណើរការដាក់ពាក្យ

សិស្សអន្តរជាតិដែលមានបំណងដាក់ពាក្យសំរាប់កន្លែងមួយនៅមហាវិទ្យាល័យ St Leonard, ត្រូវបញ្ជូន៖

1. បបែបទដាក់ពាក្យសិស្សអន្តរជាតិពេញលេញមួយ
2. ច្បាប់ចម្លងសំបុត្រកំណើតសិស្សមួយច្បាប់, ប៉ាស្ព័រ, វីសា និង/ឬលិខិតបញ្ជាក់សញ្ជាតិ
3. ច្បាប់ចម្លងរបាយការណ៍សាលាថ្មីបំផុតដែលត្រូវបានបញ្ជាក់ និងបកប្រែចំនួន២ច្បាប់
4. ច្បាប់ចម្លងតេស្តដែលពាក់ព័ន្ធនឹងការអប់រំបន្ថែមណាមួយដែលត្រូវបានធ្វើ និងព័ត៌មានផ្សេងណាមួយដែលនឹងគាំទ្រការដាក់ពាក្យរបស់សិស្ស ហើយសំរាប់
5. សិស្សដែលកំពុងដាក់ពាក្យចូលក្នុងឆ្នាំប្រុងប្រៀប ដល់ឆ្នាំទី៤ដែលមានប្រវត្តិភាសាមិនមែនជាភាសាអង់គ្លេស និង/ឬភាសាអង់គ្លេសមិនមែនជាភាសាណែនាំនៅសាលាបច្ចុប្បន្នរបស់ពួកគេ, ពួកគេត្រូវបានទាមទារអោយបង្ហាញថាពួកគេមានកំរិតភាសាអង់គ្លេសដែលអាចចូលរួមសកម្មភាពក្នុងថ្នាក់បានយ៉ាងពេញលេញ។ការដាក់ពាក្យសំរាប់សិស្សចូលឆ្នាំទី៥ និងលើនឹង ត្រូវផ្តល់ច្បាប់ចម្លងលទ្ធផលតេស្ត( AEAS )សេវាកម្មវាយតម្លៃការអប់រំរបស់សិស្សអូស្ត្រាលីមួយច្បាប់។

សំរាប់ព័ត៌មានបន្ថែមពីតេស្ត AEAS, សូមទំនាក់ទំនង AEAS៖+ 61 3 9654 0077, admin@aeas.com.au ឬ www.aeas.com.au

ពេលដែលមហាវិទ្យាល័យទទួលបានឯកសារដែលទាមទារហើយ នាយកទំនាក់ទំនងអន្តរជាតិ និងប្រធានសាលាដែលពាក់ព័ន្ធនឹងត្រួតពិនិត្យការដាក់ពាក្យរបស់អ្នក។បន្ទាប់ពីនេះ, អ្នកដាក់ពាក្យ, គ្រួសាររបស់ពួកគេ និង/ឬភ្នាក់ងារអប់រំដែលបានតែងតាំងនឹងត្រូវបានប្រាប់ពីលទ្ធផលនៃការដាក់ពាក្យ។

ប្រសិនបើការដាក់ពាក្យជោគជ័យ, លិខិតផ្តល់ជូននឹងត្រូវធ្វើឡើងស្របតាមល័ក្ខខ័ណ្ឌដែលបានធ្វើបានដូចខាងក្រោម៖

1. លទ្ធផលនៃការធ្វើតេស្ត AEAS ក្រោយទទួលបានជោគជ័យដែលបង្ហាញថាសិស្សបានត្រៀមខ្លួនរួចជាស្រេចដើម្បីផ្លាស់ប្តូរទៅថ្នាក់ធម្មតា, ហើយនឹង
2. ការសំភាសន៍ជាមួយប្រធានសាលាដើម្បីធ្វើការសម្រេចចុងក្រោយលើមុខវិជ្ជាដែលបានជ្រើស។

## ការវាយតម្លៃភាសាអង់គ្លេស

សិស្សគ្រប់គ្នាដែលដាក់ពាក្យចូលមហាវិទ្យាល័យឆ្នាំទី៥ និងលើនឹង ហើយដែលភាសាអង់គ្លេសមិនមែនជាភាសាទីមួយរបស់ពួកគេ និង/ឬភាសាអង់គ្លេសមិនមែនជាភាសាណែនាំនៅសាលាបច្ចុប្បន្នរបស់ពួកគេ, ពួកគេត្រូវបានទាមទារអោយធ្វើតេស្តវាយតម្លៃភាសាអង់គ្លេសដែលត្រូវបានត្រួតពិនិត្យដោយAEAS។តេស្តនេះត្រូវធ្វើឡើងមុនពេលដាក់ពាក្យចូលរៀន ហើយវាអាចធ្វើបាននៅប្រទេសអូស្ត្រាលី ឬនៅប្រទេសដើមកំណើតរបស់សិស្ស។

សំរាប់ពាក្យស្នើសុំផ្សេងទៀត ( ថ្នាក់ប្រុងប្រៀបដល់ឆ្នាំទី៤ ) កំរិតជំនាញភាសាអង់គ្លេសរបស់សិស្សនឹងត្រូវបានវាយតម្លៃតាមរយៈការសំភាសន៍, ការពិនិត្យសំណេរ, ការវាយតំលៃកំរិតនៃការអានរបស់សិស្ស ហើយផ្នែកមួយណាដែលត្រូវបានគេចាត់ទុកថាចាំបាច់, ថ្នាក់រយៈពេលខ្លីនឹងត្រូវរៀបចំឡើង ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីសមត្ថភាពភាសាអង់គ្លេសរបស់និស្សិត។

## លិខិតផ្តល់ជូន

ការផ្តល់ជូនសំរាប់ការចុះឈ្មោះនឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ដើម្បីទទួលយកការផ្តល់ជូននេះ, គ្រប់ថ្លៃឈ្នួល និងថ្លៃសេវាដែលបានបញ្ជាក់នៅក្នុងនេះត្រូវតែបង់អោយហើយតាមកាលបរិច្ឆេទកំណត់ដើម្បីបញ្ជាក់ការទទួលយក។ប្រសិនបើការទូទាត់មិនត្រូវបានទទួលការផ្តល់ជូនអាចត្រូវបានដកចេញតាមការសំរេចចិត្តរបស់មហាវិទ្យាល័យ។

នៅពេលទទួលបានថ្លៃឈ្នួល និងថ្លៃសេវាកម្មដែលបានបញ្ជាក់រួចហើយ មហាវិទ្យាល័យនឹងចេញលិខិតបញ្ជាក់ការចុះឈ្មោះ (COE), និងលិខិតគ្រប់ដណ្តប់ថែទាំសុខភាពនិស្សិតបរទេស (OSHC) , បន្ថែមលើលិខិតផ្តល់ជូនអ្នកតម្រូវឱ្យដាក់ពាក្យសុំទិដ្ឋាការនិស្សិត។ពាក្យសុំទិដ្ឋាការត្រូវតែដាក់ពាក្យសុំនៅស្ថានទូតអូស្ត្រាលី រឺក៏ គណៈកម្មការជាន់ខ្ពស់អូស្ត្រាលី។

ប្រសិនបើសិស្សពន្យារពេលចុះឈ្មោះចូលរៀនពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងលិខិតផ្តល់ជូន នោះស្ថានភាពទិដ្ឋាការរបស់សិស្សអាចនឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

## ថ្លៃឈ្នួល និងថ្លៃសេវាកម្ម, និងការគ្របដណ្តប់លើសុខភាព

សូមមើលខិតប័ណ្ណ ថ្លៃឈ្នួល និងថ្លៃសេវាកម្មសិស្សអន្តរជាតិ។

## សេចក្តីជូនដំណឹងអំពីការដកយកវិញ

និស្សិតអន្តរជាតិត្រូវបានហាមឃាត់មិនឱ្យផ្ទេរពីមហាវិទ្យាល័យ St Leonard ទៅមហាវិទ្យាល័យផ្តល់ការអប់រំមួយផ្សេងទៀតក្នុងរយៈពេល៦ខែគិតចាប់ពីថ្ងៃចាប់ផ្តើម។បន្ទាប់ពីរយៈពេលដំបូងនៃការចុះឈ្មោះនេះ, ការជូនដំណឹងមួយជាលាយលក្ខណ៍អក្សរទៅអ៊ីម៉ែល enrolment@stleonards.vic.edu.au ត្រូវធ្វើមុនយ៉ាងហោចណាស់រយៈពេលមួយឆមាស ហើយចាំបាច់ត្រូវផ្ញើទៅនាយកទំនាក់ទំនងអន្តរជាតិ, ប្រាប់ពីចេតនារបស់សិស្សក្នុងការដកពាក្យចេញ។ប្រសិនបើដំណើរការនេះមិនត្រូវបានអនុវត្តតាមការគិតថ្លៃស្មើនឹងថ្លៃសេវាមួយឆមាសនឹងត្រូវអនុវត្ត។

## គោលការណ៍សងប្រាក់វិញទៅសិស្សអន្តរជាតិ

ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលចុះឈ្មោះមិនអាចសងវិញបានទេ ប្រសិនបើការដាក់ពាក្យសុំរបស់សិស្សត្រូវបានលុបចោល។

1. កន្លែងណាដែលការចុះឈ្មោះត្រូវបានដកចេញជាលាយលក្ខណ៍អក្សរច្រើនជាងមួយត្រីមាស មុនកាលបរិច្ឆេទចាប់ផ្តើម ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃឈ្នួល Homestay ដកចេញថ្លៃលុបចោល $1,000 អាចសងវិញបាន។ ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ គឺមិនអាចអាចសងវិញបានទេ ហើយក៏មិនអាចផ្ទេរបានឡើយ។
2. កន្លែងណាដែលការចុះឈ្មោះត្រូវបានដកចេញជាលាយលក្ខណ៍អក្សរតិចជាងមួយត្រីមាស កាលបរិច្ឆេទចាប់ផ្តើម ថ្លៃដាក់ពាក្យសុំ ថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ រួមជាមួយនឹង 25% នៃថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ គឺមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃឈ្នួល Homestay អាចសងវិញបាន។។
3. កន្លែងណាដែលភស្តុតាងត្រូវបានផ្តល់ឱ្យ ថាពាក្យសុំទិដ្ឋាការត្រូវបានបដិសេធដោយក្រសួងកិច្ចការផ្ទៃក្នុងរបស់ប្រទេសអូស្ត្រាលី ថ្លៃឈ្នួលបង្រៀនប្រចាំឆ្នាំ ថ្លៃធានារ៉ាប់រងសុខភាព និងថ្លៃ Homestay គឺអាចសងវិញបាន។ ថ្លៃឈ្នួលដាក់ពាក្យសុំ និងថ្លៃឈ្នួលបញ្ជាក់ការចុះឈ្មោះ គឺមិនអាចសងវិញ ឬក៏អាចផ្ទេរបានឡើយ។

4. បន្ទាប់ពីការចាប់ផ្តើមចុះឈ្មោះចូលរៀននៅវិទ្យាល័យ  ហើយកន្លែងណាដែលមិនបានផ្តល់ការជូនដំណឹង ក្នុងត្រីមាសសាលាពេញអំពីការដកចេញពាក្យសុំទេនោះ ការគិតថ្លៃស្មើនឹងថ្លៃឈ្នួលមួយត្រីមាសនឹងត្រូវអនុវត្ត។
5. ប្រសិនបើសិស្សផ្លាស់ប្តូរស្ថានភាពទិដ្ឋាការ ( ឧទាហរណ៍ ក្លាយជាអ្នកស្នាក់នៅបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ) ថ្លៃឈ្នួលសិស្សអន្តរជាតិពេញលេញនឹងនៅតែត្រូវបង់សម្រាប់អំឡុងពេលនៃឆមាសនោះ។
6. ការសងប្រាក់វិញទាំងអស់នឹងត្រូវគិតជាប្រាក់ដុល្លារអូស្ត្រាលី ហើយនឹងត្រូវបង់ជូនភាគីដើមដែលបានធ្វើការទូទាត់ប្រាក់។
7. ដើម្បីទាមទារការសងប្រាក់វិញ សិស្សត្រូវជូនដំណឹងទៅអ្នកគ្រប់គ្រងទទួលចូលសិស្សអន្តរជាតិជាលាយលក្ខណ៍អក្សរ អំពីគោលបំណងរបស់ពួកគេក្នុងការលុបចោលការចុះឈ្មោះ និងទាមទារការសងប្រាក់វិញ។ បន្ទាប់ពីទទួលបានការជូនដំណឹង កន្លែងណាដែលបានយល់ព្រមការសងប្រាក់វិញនឹងត្រូវដំណើរការ ហើយបញ្ចប់ក្នុងរយៈពេលប្រាំមួយសប្តាហ៍គិតចាប់ពីថ្ងៃទទួល។
8. កិច្ចព្រមព្រៀងនេះមិនដកសិទ្ធិរបស់វិទ្យាល័យ ក្នុងការចាត់វិធានការបន្ថែមដើម្បីប្រមូលថ្លៃឈ្នួល និងការគិតថ្លៃណាមួយដែលនៅជំពាក់វិទ្យាល័យឡើយ។
9. កិច្ចព្រមព្រៀងនេះ និងភាពអាចរកបាននៃដំណើរការបណ្តឹងតវ៉ា និងបណ្តឹងតវ៉ាមិនយល់ស្របរបស់វិទ្យាល័យ មិនដកសិទ្ធិរបស់សិស្សក្នុងការចាត់វិធានការក្រោមច្បាប់ការពារអ្នកប្រើប្រាស់របស់ប្រទេសអូស្ត្រាលីទេ។

## គោលការណ៍សារទុក្ខព្រួយរបស់សិស្សអន្តរជាតិ

ការសោកស្តាយដែលនាំមកដោយសិស្ស / ឪពុកម្តាយ / អាណាព្យាបាលផ្សេងទៀតប្រឆាំងនឹងសិស្សម្នាក់ទៀតនឹងត្រូវបានដោះស្រាយក្រោមគោលនយោបាយប្រឆាំងនឹងការគំរាមកំហែង ( សិស្ស ) គោលនយោបាយប្រឆាំងនឹងការគំរាមកំហែង ( សិស្ស ) និងគោលនយោបាយសុខុមាលភាពសិស្ស។

## ដំណោះស្រាយបណ្តឹងក្រៅផ្លូវការ

1. ដំបូង, មហាវិទ្យាល័យស្នើរអោយមានការដោះស្រាយបញ្ហាដោយ ការសម្របសម្រួល/ ដំណោះស្រាយក្រៅផ្លូវការរបស់បណ្តឹង។
2. សិស្ស / ឪពុកម្តាយ / អាណាព្យាបាលគួរទាក់ទងគ្រូរបស់សិស្ស / ប្រធានថ្នាំ / ប្រធានសាលាក្នុងករណីដំបូងដើម្បីប៉ុនប៉ងការសម្រុះសម្រួល / ដំណោះស្រាយក្រៅផ្លូវការនៃពាក្យបណ្តឹង។
3. ប្រសិនបើបញ្ហានេះមិនអាចត្រូវបានដោះស្រាយតាមរយៈការស្រមុះស្រមួល, បញ្ហានេះនឹងត្រូវបញ្ជូនទៅនាយកសាលា និងបណ្តឹងជាផ្លូវការផ្ទៃក្នុងរបស់មហាវិទ្យាល័យ ហើយនិតិវិធីក្នុងការដោះស្រាយឧទ្ធរណ៍នឹងមកតាមក្រោយ។

## បណ្តឹងតវ៉ាជាផ្លូវការ ឬនីតិវិធីដោះស្រាយបណ្តឹងឧទ្ធរណ៍

1. ដំណើរការនៃនីតិវិធីបណ្តឹងតវ៉ានេះគឺជាការសម្ងាត់ហើយរាល់បណ្តឹងតវ៉ា ឬបណ្តឹងឧទ្ធរណ៍គឺជាបញ្ហារវាងភាគីពាក់ព័ន្ធនិងអ្នកដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងដំណើរការដោះស្រាយបណ្តឹងតវ៉ា។
2. សិស្ស/ឪពុកម្តាយ/អាណាព្យាបាលត្រូវជូនដំណឹងមហាវិទ្យាល័យជាលាយល័ក្ខអក្សរពីជម្លោះ និងព័ត៌មានលម្អិតនៃពាក្យបណ្តឹង ឬបណ្តឹងសាទុក្ខ។
3. ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ឬបណ្តឹងសាទុក្ខត្រូវដាក់ជូននាយកសាលា។
4. នៅពេលដែលដំណើរការបណ្តឹងតវ៉ា និងការប្តឹងឧទ្ធរណ៍ផ្ទៃក្នុងកំពុងត្រូវបានគេចូលមើលដោយសារមានការជូនដំណឹងផ្តល់ទៅមហាវិទ្យាល័យមានចេតនារាយការណ៍ពីនិស្សិតលើការមិនពេញចិត្តក្នុងការចូលរួមក្នុងវគ្គសិក្សា, មិនពេញចិត្តភាព

រកែចម្រើនរបស់វគ្គសិក្សា,ឬ ផ្អាក ឬការលុបចោលការចុះឈ្មោះ, សិស្ស /ឪពុកម្ដាយ /អាណាព្យាបាលមានរយៈពេល ២០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងដែលត្រូវដាក់បណ្ដឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ។

5. ដំណើរការបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងផ្ទៃក្នុងមានសម្រាប់សិស្សដោយមិនគិតថ្លៃ។
6. អ្នកប្ដឹងម្នាក់ៗមានឱកាសបកស្រាយករណីរបស់ខ្លួនទៅកាន់នាយកសាលា។
7. សិស្ស/ឪពុកម្ដាយ/អាណាព្យាបាលអាចមកជាមួយ និងអាចទទួលជំនួយពីបុគ្គលគាំទ្រម្នាក់ ឧ.មិត្តម្នាក់/គ្រូម្នាក់/សាច់ញាតិម្នាក់ដែលមិនពាក់ព័ន្ធនឹងសារទុក្ខ (មេធាវី និង/ឬភ្នាក់ងារអប់រំមិនទទួលយកជាបុគ្គលគាំទ្រទៅតំណាក់កាលរបស់ដំនើរការដោះស្រាយបណ្ដឹងនេះទេ) បាននៅគ្រប់ការជួបជុំដែលពាក់ព័ន្ធទាំងអស់។
8. ដំណើរការបណ្ដឹងតវ៉ាជាផ្លូវការនឹងចាប់ផ្ដើមក្នុងរយៈពេលដប់ថ្ងៃធ្វើការ (ថ្ងៃផ្សេងៗក្រៅពីថ្ងៃសៅរ៍ថ្ងៃអាទិត្យឬថ្ងៃឈប់សំរាកសាធារណៈក្នុងកំឡុងពេលកំណត់) នៃបណ្ដឹងតវ៉ាឬប្ដឹងឧទ្ធរណ៍ជាមួយនាយកសាលា។
9. ពេលដែលនាយកសាលាបានធ្វើការសំរេចចិត្តលើបណ្ដឹង ឬបណ្ដឹងឧទ្ធរណ៍ហើយ, សិស្ស/ឪពុកម្ដាយ/អាណាព្យាបាលនឹងទទួលបានដំណឹងជាលាយល័ក្ខអក្សរពីលទ្ធផល និងហេតុផលរបស់លទ្ធផល។
10. ប្រសិនបើនិតិវិធីសារទុក្ខឃើញថាលំអៀងទៅលើសិស្ស, មហាវិទ្យាល័យSt Leonard នឹងអនុវត្តការសំរេចចិត្ត និងការកែប្រែ និងសកម្មភាពការពារដែលចាំបាច់ភ្លាមៗ។
11. កំណត់ត្រាឯកសារទាំងអស់ទាក់ទងនឹងសារទុក្ខ, បណ្ដឹង ឬបណ្ដឹងឧទ្ធរណ៍ និងដំនើរការ ហើយនឹងលទ្ធផលរបស់វានឹងត្រូវបានកត់ត្រាយ៉ាងល្អិតល្អន់លើឯកសាររបស់សិស្ស និងនៅក្នុងឯកសារសារទុក្ខសិស្សអន្តរជាតិ។ កំណត់ត្រានឹងត្រូវរក្សាទុកទាំងជាច្បាប់ចម្លងសុសវែរ និងជាច្បាប់ចម្លងក្រដាស។
12. មហាវិទ្យាល័យ St Leonard ធ្វើការសំរេចនីតិវិធីដោះស្រាយបណ្ដឹងតវ៉ាទាំងអស់ក្នុងរយៈពេលដប់ថ្ងៃនៃថ្ងៃធ្វើការ (លើកលែងតែ នេះត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធភាព, ក្នុងករណីនេះនិស្សិត / អាណាព្យាបាល / ក្រុមគ្រួសារនឹងត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទរំពឹងទុកសម្រាប់ការបញ្ចប់) ។
13. មហាវិទ្យាល័យនឹងអោយដំណឹងដល់សិស្សជាលាយលក្ខណ៍អក្សរថាការចុះឈ្មោះចូលរៀនរបស់សិស្សនឹងត្រូវបានរក្សាទុកខណៈពេលដែលបណ្ដឹងសាទុក្ខកំពុងបន្ត។ សម្រាប់រយៈពេលនៃដំណើរការបណ្ដឹងឧទ្ធរណ៍, និស្សិតចាំបាច់ត្រូវរក្សាការចុះឈ្មោះ និងបន្តចូលរៀននៅគ្រប់ថ្នាក់ទាំងអស់តាមធម្មតា។

## ដំណើរការបណ្ដឹងឧទ្ធរណ៍ខាងក្រៅ

ប្រសិនបើនីតិវិធីនៃការត្អូញត្អែរជាផ្លូវការរបស់មហាវិទ្យាល័យមិនលំអៀងទៅខាងសិស្ស ឬសិស្សមិនពេញចិត្តនឹងលទ្ធផលនៃបណ្ដឹងតវ៉ានោះ, សិស្សនឹងទទួលបានការជូនដំណឹងអំពីដំណើរការបណ្ដឹងតវ៉ាខាងក្រៅនិងដំណើរការបណ្ដឹងឧទ្ធរណ៍ដែលមានសម្រាប់ពួកគេដោយចំណាយតិចបំផុត ឬមិនគិតថ្លៃ។

ភ្នាក់ងារខាងក្រៅដែលត្រូវបានប្រើសម្រាប់បណ្ដឹងតវ៉ានិងដំណើរការបណ្ដឹងឧទ្ធរណ៍ខាងក្រៅរបស់មហាវិទ្យាល័យ St Leonard គឺ៖

មជ្ឈមណ្ឌលបញ្ចប់ជម្លោះ

235 Queen Street

Melbourne VIC 3000

P:+ 61 3 9603 8370

នៅពេលដែលអ្នកសម្រុះសម្រួលបានណែនាំនូវសកម្មភាព, ភាគីទាំងពីរត្រូវគោរពតាមអនុសាសន៍និងបញ្ឈប់ជម្លោះបន្តទៀត។

NULLA DIES SINE LINEA

St Leonard's College

An education for life.

**St Leonard's College**
163 South Road, Brighton East VIC 3187
Bunurong Country

stleonards@stleonards.vic.edu.au
**stleonards.vic.edu.au**

**P** (+61 3) 9909 9300
ABN 52 006 106 556

CRICOS 00343K